00152347

**Declassified to Public**
**06 September 2012**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ: | ០០២/១៤-០៨-២០០៦-អ.វ.ត.ក-ការិយាល័យសហព្រះរាជអាជ្ញា -74- C13 |
| លេខស៊ើបសួរ: | ០០១/១៨-០៧-២០០៧ |
| ឈ្មោះសំណុំរឿង: | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ |
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន: | ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ |
| ភាគីបញ្ជូន: | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម: | ភាសាអង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារចម្លងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le)...13...ខែ(Month/Mois)...NOV...
ឆ្នាំ (Year/Année)...2007...
ក្រឡាបញ្ជី/ Greffier ...NUP SOTHUN VICHET...

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា**
**ចំពោះសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី តទៅចំពោះដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេតលើឈ្មោះ កាំង ហ្គេចអ៊ាវ ហៅឌុច កាលពីថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០០៧**

---

**បញ្ជូនដោយ:**

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក រ៉ូប៊ើត ពីទីត

ORIGINAL DOCUMENT
RECEIVED ON 12/11/2007
AT: 16:16' BV
NUP SOTHUNVICHET
VICHET
ACTING CASE FILE
OFFICER

**ជូន:**

**អង្គបុរេជំនុំជម្រះ៖**
លោក ប្រាក់ គឹមសាន
លោក ន័យ ថុល
លោក ហ៊្វូត រុទ្ធី
លោកស្រី កនិត្កា ឡាហ៊ុយ
លោក រ៉ូវ៉ាន់ ដោនីង

**សហចៅក្រមស៊ើបអង្កេត៖**
លោក យូ ប៊ុនឡេង
លោក ម៉ាកសែល ឡឺម៉ុង

**មេធាវីការពារក្តី ៖**
លោក កា សាវុធ
លោក ហ្រ្វង់ស្វ័រ រូ

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៤-០៨-២០០៦-ECCC-OCP

## ប្រវត្តិនៃនីតិវិធី

១. កាលពីថ្ងៃទី៣១ កក្កដា ឆ្នាំ២០០៧ បន្ទាប់ពីសវនាការដេញដោល សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្គេចអ៊ាវ (“ជនត្រូវចោទ”) សំរាប់រយៈពេលមួយ (០១) ឆ្នាំ ក្នុងអំឡុងពេលនៃការស៊ើបសួរ ប្រឆាំងនឹងរូបគាត់ ។

២. ជនត្រូវចោទបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់នេះ តាមរយៈសេចក្តីថ្លែងសំអាងធ្វើឡើងជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ និងថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ (“បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី”) ។ សហព្រះរាជអាជ្ញា បានបញ្ជូនចម្លើយតបចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ (“ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា”) ។ សវនាការណែនាំ ត្រូវបានកំណត់យកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាអសាធារណៈ និង សវនាការជាសាធារណៈដែលត្រូវធ្វើឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ នៅថ្ងៃទី២០ និង២១ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

៣. ប្រធានអង្គបុរេជំនុំជម្រះ បានចេញសេចក្តីជូនដំណឹងជាសាធារណៈមួយ កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ ២០០៧ អញ្ជើញគ្រប់ភាគីទាំងអស់ដែលមានចំណាប់អារម្មណ៍ឲ្យដាក់ *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ជាលាយលក្ខណ៍អក្សរ ។ អង្គបុរេជំនុំជម្រះបានផ្តល់ពេលវេលាដល់គូភាគី រហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ដើម្បីឆ្លើយតបចំពោះ *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទាំងអស់នេះ ។ ឯកសារនេះបង្កើតបានជាទម្រង់នៃមូលដ្ឋាន នៃការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះ *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទាំងនោះ ។

៤. សហព្រះរាជអាជ្ញាបានឃើញ និងបានអាន *សារណារបស់អ្នកដែលមិនមែនជាភាគគីនៃរឿងក្តី* ចំនួនប្រាំមួយ (០៦) (*“សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី”*) ដូចខាងក្រោម ៖

(i) Stan STARYGIN សាស្ត្រាចារ្យច្បាប់ និងកិច្ចការទំនាក់ទំនងអន្តរជាតិ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ (“សារណារបស់ STARYGIN”) ។

(ii) Jeffrey KAHAN ទីប្រឹក្សាច្បាប់ និងកិច្ចការអភិវឌ្ឍន៍ នៃគំរោងអ្នកការពារក្តីកម្ពុជា ចុះថ្ងៃទី២ ខែ តុលា ឆ្នាំ២០០៧ (“សារណារបស់ Kahan”) ។

00152349



(iii) គណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្សកម្ពុជា ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ ("សារណារបស់ CHRAC") ។

(iv) មជ្ឈមណ្ឌលសំរាប់ការអភិវឌ្ឍន៍កម្ពុជា/គំរោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ី ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ ២០០៧ ("សារណារបស់ CSD/AJII") ។

(v) Anne HEINDEL ទីប្រឹក្សាច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សារណាបានដាក់ជូនទៅតាមសមត្ថភាពរបស់គាត់ផ្ទាល់ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៧ ("សារណារបស់ Heindel") ។

(vi) David SCHEFFER សាស្ត្រាចារ្យច្បាប់ និងជាអតីតឯកអគ្គរដ្ឋទូតទទួលបន្ទុក បញ្ហាឧក្រិដ្ឋកម្ម សង្គ្រាមដែលមិនមានចុះកាលបរិច្ឆេទ ("សារណារបស់ Scheffer") ។

៥. សហព្រះរាជអាជ្ញាបានទទួល *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទាំងនេះ នៅថ្ងៃសុក្រ ទី២៦ ខែ តុលា ឆ្នាំ២០០៧ ។ ដោយពិចារណាលើពេលវេលាដែលផ្តល់ជូនសំរាប់ការឆ្លើយតប សហព្រះរាជអាជ្ញាសូមរក្សាសិទ្ធិដើម្បីលើកឡើង ឬ អភិវឌ្ឍបន្ថែមទៀតនៅក្នុងសវនាការផ្ទាល់មាត់ នូវបញ្ហាណាមួយនៃបញ្ហាទាំងអស់ដែលមាននៅក្នុង *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ។

សូមដាក់ជូនដោយសេចក្តីគោរពអំពីយើងខ្ញុំ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧
**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក** Robert PETIT